# ប្រាសាទរកាជន្ទឹង

ប្រាសាទរកាជន្ទឹង[១] មានទីតាំងនៅភូមិរកាជន្ទឹង ឃុំរកាជន្ទឹង ស្រុកស៊ីធរកណ្ដាល ខេត្តកណ្ដាល។ តាមលោក ឡាហ្សង់ហ្គីយេ ពិពណ៌នាថា ប្រាសាទនេះមានប្រាង្គចំនួន៣ (រូបលេខ១) ធ្វើពីថ្មបាយក្រៀម មានប្លង់រាងជាការ៉េ បែរមុខទៅទិសខាងកើត និងឈរជាជួរត្រង់តាមអ័ក្សជើងត្បូង។ ជាក់ស្ដែង ប្រាង្គរបស់ប្រាសាទនេះនៅឃើញមាន២ គឺខាងត្បូង និងកណ្ដាល ដែលធ្វើពីថ្មបាយក្រៀម (លីម៉ូនីត) លំអដោយគ្រឿងស្ថាបត្យកម្មជាថ្មភក់ពណ៌ប្រផេះ។ នៅខាងជើងបង្អស់មានគ្រឹះរបស់ប្រាង្គមួយទៀតធ្វើពីឥដ្ឋ និងស៊ុំទ្វារនៅខាងកើតធ្វើពីថ្មភក់ពណ៌ប្រផេះ។ សំណង់ខាងជើងនេះរលំបាក់ស្ទើរអស់ទៅហើយ។

តាមរចនាសម្ព័ន្ធជាក់ស្ដែងបង្ហាញថា ប្រាង្គទាំង៣របស់ប្រាសាទនេះមិនត្រូវបានសាងសង់ក្នុងពេលជាមួយគ្នានោះទេ ពោលគឺប្រាង្គខាងត្បូង និងកណ្ដាលអាចជាប្រាង្គដែលកសាងជាមួយគ្នា រីឯប្រាង្គខាងជើងដែលបាក់រលំនោះអាចត្រូវបានសាងសង់មុន (ប្រាសាទដើម) ឬជាសំណង់ក្រោយ។ មូលហេតុគឺថាៈ

.សម្ភារៈសំណង់របស់ប្រាង្គខាងត្បូងនិងកណ្ដាលដូចគ្នា គឺថ្មបាយក្រៀម និងថ្មភក់

.សម្ភារៈសំណង់ខាងជើង គឺឥដ្ឋ និងថ្មភក់

.ប្រាង្គខាងត្បូង និងកណ្ដាលសង់នៅលើខឿនថ្មបាយក្រៀមដាច់ដោយឡែកពីប្រាង្គខាងជើង

ចំនុចនេះ យើងអាចសន្និដ្ឋានបានថា សំណង់ប្រាង្គខាងជើងអាចជាប្រាសាទចាស់មួយ ក្រោយមកបានរលំបាក់អស់ទៅ។ ក្រោយមក គេបានមកស្ថាបនាប្រាង្គ២ផ្សេងទៀតនៅខាងត្បូងប្រាង្គប្រាសាទចាស់នេះ ហើយគោលបំណងនៃការស្ថាបនាប្រាសាទថ្មីនេះ គឺគេកសាងតែប្រាង្គ២សំខាន់ប៉ុណ្ណោះ អាចជាប្រាសាទសំរាប់ព្រះវិស្ណុ ព្រោះតាមចំលាក់នៅលើផ្ដែរខាងជើងរបស់ប្រាង្គខាងត្បូងបង្ហាញអំពីចំលាក់រឿងកូរសមុទ្រទឹកដោះ។

[១] E. Lunet de Lajonquiere, (1902:171-175)

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា

## ១. ប្រាង្គខាងត្បូង

ប្រាង្គខាងត្បូង (រូបលេខ២) សង់នៅលើកំពល ឬខឿនថ្មបាយក្រោមជាមួយនិងប្រាង្គកណ្តាល តួធ្វើអំពីថ្មបាយក្រៀម និងមានទ្វារនៅទិសខាងកើត អមដោយទ្វារបញ្ឆោត៣ផ្សេងទៀតនៅតាមទិសនីមួយៗ។ គ្រឿងរបស់ទ្វារទាំងនេះ រួមមានស៊ុំទ្វារ សសរផ្អោប សសរពេជ្រ និងផ្តែរសុទ្ធសឹងតែធ្វើអំពីថ្មភក់ពណ៌ប្រផេះទាំងអស់។ ចំណែកហោជាងធ្វើអំពីថ្មបាយក្រៀមដូចតួប្រាសាទដែរ។ សព្វថ្ងៃ ប្រាង្គនេះបានរលំបាក់អស់នៅផ្នែកកំពូល គឺនៅសល់ប្រហែលកំពស់៥ម៉ែត្រពីខឿនខាងក្រោម។ ប្លង់ខាងក្នុងរបស់ប្រាង្គនេះមានរាងការ៉េ ឯខាងក្រៅមានរាងជាការ៉េដែរ តែមានជ្រុងចំនួន៥ផ្ទត់តាមជ្រុងនីមួយៗ។ សសរផ្អោបរបស់ប្រាង្គនេះធ្វើអំពីថ្មភក់ ដោយមានចែកចេញជាក្បាលសសរ តួសសរ និងបាតសសរ។ ក្នុងចំណោមសសរផ្អោបទាំង៤ទិសនេះ មានតែសសរផ្អោបនៅទ្វារខាងកើត និងខាងជើងទេដែលមានក្បាច់លំអ រីឯសសរផ្អោបនៅទ្វារខាងត្បូង និងខាងលិចមិនមានក្បាច់លំអទេ ប្រហែលធ្វើមិនទាន់រួច (រូបលេខ៣)។

សសរពេជ្ររបស់ទ្វារខាងកើតបានបាត់អស់ នៅសល់តែសសរពេជ្រនៅតាមទ្វារបញ្ឆោទទាំង៣។ ដូចនេះសសរពេជ្រដែលនៅសល់មានចំនួន៦ ធ្វើអំពីថ្មភក់ពណ៌ប្រផេះ និងមានក្បាច់លំអដូចគ្នាទាំងអស់។ សសរពេជ្ររបស់ប្រាង្គនេះមានរាង៦ជ្រុង (បញ្ចកោណ) ចែកចេញជាក្បាច់ចិញ្ចៀន១/២ ១/៤ ក្បាលសសរ ជើងសសរ និងបាតសសរ។

ផ្តែររបស់ទ្វារខាងកើតបានបាត់ទៅហើយ នៅសល់តែផ្តែរលើទ្វារបញ្ឆោទទាំង៣ទិសប៉ុណ្ណោះ។ ផ្តែរទាំង៣នេះមានទំហំប៉ុនៗគ្នា តែមានក្បាច់លំអខុសៗគ្នា។ ផ្តែរទ្វារខាងត្បូងនៅស្ថានភាពល្អស្មើរ៨០ភាគរយ ដែលអាចអោយយើងធ្វើការសិក្សាវិភាគលើក្បាច់លំអ និងរចនាបថសិល្បៈរបស់ផ្តែរនេះបាន។ វត្តមាននៃក្បាច់មេដាយ៉ុងនៅចំកណ្តាលផ្ទៃផ្តែរ បង្ហាញពីចំលាក់ក្បាលសត្វតោ ឬសត្វចំលែក ឬកាលា ដែលមានខ្នាក់ក្បាច់ដងផ្ចូចេញពីមាត់បែរទៅរកខាងក្រៅនៃផ្ទៃផ្តែរ។ ក្បាលសត្វនេះស្ថិតនៅខាងក្រោមនៃផ្ទៃផ្តែរ និងមានដៃពីរចាប់កាន់ផ្នែកខាងគល់នៃក្បាច់ដងផ្ចូ ដែលជាលក្ខណៈពិសេសដែលគេឃើញលេចចេញយ៉ាងច្បាស់ក្នុងរចនាបថឃ្លាំង (រូបលេខ២)។ រីឯផ្តែរខាងលិចនៅមានស្ថានភាព៦០ភាគរយ ដែលយើងអាចសិក្សាពិពណ៌នាបាន។ ផ្នែកកណ្តាលរបស់ផ្តែរបាន

សិករេចរិលអស់ ជាហេតុមិនអាចអោយយើងដឹងថាមានចំលាក់ ឬជារូបអ្វីដូចផ្តែរខាងត្បូងបានទេ។ ចំពោះក្បាច់ដងផ្ចូ ផ្ទៃខាងលើ ផ្ទៃខាងក្រោម និងក្បាច់ចុងនៃក្បាច់ដួង គឺមានចំលាក់ដូចគ្នាទៅនិងផ្តែរខាងត្បូង តែនៅលើចុងសង្ខាងនៃដងផ្ចូមានលេចចេញនូវចំលាក់សត្វសេះឈរបែរមុខចូលទៅរកផ្ទៃផ្តែរ។ ចំណែកគែមខាងលើរបស់ផ្តែរមានឆ្លាក់ជាបាច់ផ្កា ឬជាគុបភ្ញើងមួយជួរ មានចំនួនប្រហែល២៧។ គែមខាងលើ និងផ្ទៃផ្តែរខ័ណ្ឌដាច់ពីគ្នាដោយក្បាច់ពងត្រីមួយជួរ។ ចំណែក ផ្តែរខាងជើងនៅមានស្ថានភាពស្ទើរមួយរយភាគរយ ដែលបង្ហាញពីឈុតនៃរឿងកូរសមុទ្រទឹកដោះពេញផ្ទៃផ្តែរតែម្តង (រូបលេខ៥)។ នៅផ្នែកកណ្តាលខាងក្រោមជារូបសត្វអណ្តើក បែរក្បាលមកខាងស្តាំនៃផ្តែរ ទ្រក្បាច់សន្ទឹកត្រួតលើគ្នា (ប្រហែលតំណាងអោយភ្នំមណ្ឌរ) ហើយមានសត្វសេះមួយលេចចេញពីផ្នែកខាងក្រោយនៃអណ្តើក និងទេព(ស្រី)ម្នាក់នៅក្បែរក្បាលអណ្តើក។ បន្តទៅលើនៃខ្នងអណ្តើក គឺជាត្រគួចនៃខ្លួនពស់ (វសុគី) និងមានទេពមួយ (អាចជាព្រះវិស្ណុ ព្រោះមានដៃពីរនៅផ្នែកខាងឆ្វេង មួយអោបក្បាច់សន្ទឹក និងមួយទៀតបានបាក់បាត់) នៅពីលើខាងឆ្វេងក្នុងកាយវិការអោបក្បាច់សន្ទឹកត្រួតលើគ្នា។ នៅខាងស្តាំ ខាងក្រោមមានរូបទេព (ស្រី) មួយទំនងជាកាន់ថូ (ទឹកអម្រឹត) និងខាងលើជាទេពមួយអង្គុយបញ្ឈរជង្គង់ស្តាំដោយដៃស្តាំដាក់លើជង្គង់ និងដៃឆ្វេងដាក់លើភ្លៅឆ្វេង។ ទេពនេះអង្គុយក្នុងរង្វង់មូលមួយ គឺអាចជាព្រះសូរ្យ។ ចំពោះពស់វាសុគី គឺមានក្បាល៣ ស្ថិតនៅផ្នែកខាងស្តាំនៃផ្តែរ ហើយកាន់ទាញដោយពួកអសុរចំនួន៤។ នៅខាងក្រោមក្បាលពស់មានអសុរតូចមួយផ្សេងទៀត។ ចំណែកពួកសុរកាន់ផ្នែកដងខ្លួនរហូតដល់កន្ទុយ មានចំនួន៤ដែរ និងមានទេពតូចមួយទៀតនៅកាន់ក្រោមកន្ទុយពស់។ នៅចន្លោះអសុរ និងសុរនីមួយៗ មានក្បាច់ផ្កាឈូករីក និងផ្កាឈូកក្រពុំ។ រីឯខាងក្រោមក្បែរជើងអសុរ និងសុរ គឺមានចំលាក់ជាសត្វត្រី។ ការឆ្លាក់រឿងកូរសមុទ្រទឹកដោះនៅលើផ្តែរនៃទ្វារខាងជើងបែបនេះ គឺមានដូចគ្នាដែរនៅប្រាសាទតាទួតនៃក្រុមព្រះពិធូ។

ទ្វារទាំង៤របស់ប្រាង្គខាងត្បូងនេះសុទ្ធតែធ្វើពីថ្មភក់ពណ៌ប្រផេះ។ ទ្វារខាងកើតជាទ្វារចូល គឺផ្គុំឡើងដោយដុំថ្មចំនួន៤ដុំរៀបបន្តុំលើគ្នាជាស៊ុំមួយ។ ចំពោះទ្វារបញ្ឆោត៣ផ្សេងទៀតជា ទ្វារបិទជិត ផ្គុំឡើងដោយផ្ទាំងថ្មភក់បញ្ឈរ (មានពី៣ទៅ៤ផ្ទាំង) ជាប់គ្នា

និងធ្លាក់ចេញជារាងទ្វារ ដោយមានក្បាច់លំអជាខ្សែពកផត បញ្ឈរនិងផ្តេកជុំវិញ។ នៅចំកណ្តាលនៃបន្ទះសន្ទឹកទ្វារ គេធ្លាក់ចេញជាក្បាច់ជុំរាងការ៉េ មានចំនួន៥ពីលើចុះក្រោម។

តាមកស្តុតាងជាថ្មកក់នៅលើក្បាលសសរផ្តោបនៃទ្វារចូលខាងកើតបញ្ជាក់ថា ហោជាងរបស់ទ្វារខាងកើតត្រូវបានសាងឡើងអំពីថ្មកក់ពណ៌ប្រផេះ ព្រោះនៅមានថ្មដែលមានចំលាក់ជាក្បាលមករខ្ជាក់នាគ។ ចំណែកឯហោជាងនៅតាមទិសទាំង៣ផ្សេងទៀត គឺប្រហែលធ្វើអំពីថ្មបាយក្រៀមដូចប្រាង្គតែម្តង។ ហោជាងទាំង៣នេះពុំមានចំលាក់អ្វីទេ គឺប្រហែលជាមានការប្រើប្រាស់កំបោរបាយអរបន្ថែមសំរាប់ធ្វើក្បាច់លំអ។

## ២. ប្រាង្គកណ្តាល

ប្រាង្គកណ្តាលមានទ្រង់ទ្រាយ និងប្លង់ដូចគ្នាទៅនឹងប្រាង្គខាងត្បូងដែរ តែមានទំហំតូចជាងប្រាង្គខាងត្បូងបន្តិច។ ម្យ៉ាងទៀត ស្ថានភាពសព្វថ្ងៃរបស់ប្រាង្គនេះ គឺបាក់រលំបាត់អស់ នៅសល់ត្រឹមតួដែលមានកំពស់ប្រហាក់ប្រហែលនឹងប្រាង្គខាងត្បូងដែរ (រូបលេខ២៦)។ រចនាសម្ព័ន្ធរបស់វាសុទ្ធសឹងតែធ្វើអំពីថ្មបាយក្រៀមទាំងអស់ ទាំងសសរផ្តោប សសរពេជ្រ ហោជាង ផ្តែរ និងទ្វារបញ្ឆោត។ លើកលែងតែស៊ុំទ្វារ សសរពេជ្រ និងផ្តែររបស់ទ្វារខាងកើត ត្រូវបានសាងឡើងពីថ្មកក់ពណ៌ប្រផេះ។

សសរពេជ្ររបស់ប្រាង្គកណ្តាលនេះមានរូបរាង និងក្បាច់ដូចគ្នាទាំងស្រុងជាមួយនិងសសរពេជ្ររបស់ប្រាង្គខាងត្បូង តែខុសគ្នាត្រង់ទំហំ (តូចជាងប្រាង្គខាងត្បូង)។ សសរពេជ្ររបស់ប្រាង្គនេះមានរាង៦ជ្រុង (បញ្ចកោណ) ចែកចេញជាក្បាច់ចិញ្ចៀន១/២ ១/៤ ក្បាលសសរ ដើងសសរ និងបាតសសរ។

ផ្តែរទ្វារខាងកើតមានលក្ខណៈស្រដៀងគ្នាជាមួយផ្តែរទ្វារខាងត្បូងរបស់ប្រាង្គខាងត្បូងដែរ (រូបលេខ២៧) តែមានចំណុចខុសមួយចំនួនដូចជា៖ (១)មានទំហំតូចជាង (២)ផ្នែកខាងលើនៃផ្តែរមានក្បាច់កន្ទុយហង្សតូចជាង តែមានចំនួន៥ក្នុងម្ខាង។ (ផ្តែរប្រាង្គខាងត្បូងមានតែ៤ទេ) (៣) លើក្បាលកាលាជារូបទេពជិះលើដំរីក្បាល១ ជាព្រះឥន្ទ្រ (៤) ពុំមានគែមខាងលើទេ (ផ្តែរប្រាង្គខាងត្បូងមានរូបហង្ស១ជួរ)។

ស៊ុំទ្វារខាងកើតធ្វើអំពីថ្មកក់ពណ៌ប្រផេះ មានចំនួន៤ជុំផ្គុំភ្ជាប់ និងបន្តុបលើគ្នា។ សព្វថ្ងៃ ផ្នែកខាងលើនៃស៊ុំទ្វារនេះបាក់ជាពីរកំណាត់ តែស្ថិតនៅទីតាំងដើមដដែល។

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ចំណែកសុំទ្វារបញ្ឆោតទាំង៣ផ្សេងទៀត គឺធ្វើអំពីថ្មបាយក្រៀម ដោយគេធ្លាក់អោយចេញពងជាទ្វារ។

៣. ប្រាង្គខាងជើង

ប្រាង្គខាងជើងជាប្រាង្គតូចមួយ (រូបលេខ៨) ដែលបច្ចុប្បន្ននៅសល់តែផ្នែកខាងក្រោមបន្តិច ជាមួយនិងសុំទ្វារខាងកើតសាងអំពីថ្មភក់ពណ៌ប្រផេះ។ តាមស្ថានភាពជាក់ស្តែង ប្រាង្គនេះត្រូវបានកសាងឡើងអំពីឥដ្ឋ នៅដាច់ដោយឡែកពីប្រាង្គខាងត្បូង និងកណ្តាល (នៅលើខឿនរួមគ្នាធ្វើអំពីថ្មបាយក្រៀម) មានទ្វារចូលពីទិសខាងកើត និងទ្វារបញ្ឆោតនៅទិសទាំង៣ផ្សេងទៀត។ ប្រាង្គនេះពុំមានបន្សល់អ្វីជាសំខាន់សំរាប់ការសិក្សាលើរចនាសម្ព័ន្ធ និងរចនាបថសិល្បៈរបស់វាទេ។ តែតាមសំភារៈសំណង់ ប្រាង្គខាងជើងអាចជាប្រាសាទចាស់មួយ មុនប្រាង្គខាងត្បូង និងកណ្តាល។

សង្ខេបអត្ថបទ

ជាសង្ខេបយើងឃើញថា រកាជន្ទឹងជាប្រាសាទមានប្រាង្គ៣ ដែលអាចកសាងក្នុងពេលខុសគ្នា។ ប្រាង្គខាងជើង ជាប្រាង្គសាងអំពីឥដ្ឋលាយថ្មភក់ (សុំទ្វារ) អាចត្រូវបានស្ថាបនាមុន ហើយអាចមានប្រាង្គមួយឬពីរនៅក្បែរនោះដែរ តែក្រោយមកបានរលំបាក់បាត់អស់។ ក្រោយមក គេបានស្ថាបនាប្រាង្គ២ថ្មី ពីថ្មបាយក្រៀម និងថ្មភក់នៅខាងត្បូង។ តាមចម្លាក់នៅលើផ្តែរ បង្ហាញថាប្រាង្គទាំង២នេះអាចត្រូវបានស្ថាបនាក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (១០០២គ.ស ដល់១០៥០គ.ស) ឬក្នុងរចនាបថឃ្លាំង ដើម្បីឧទ្ទិសដល់ហិណ្ឌូសាសនា និកាយព្រះវិស្ណុ។ ទោះយ៉ាងណា យើងពុំមានសិលាចារឹកបង្ហាញអំពីការស្ថាបនាប្រាសាទ ឬប្រាង្គទាំងនេះទេ។

## ឯកសារយោង

L. de Lajonquiere,(1902), *Inventaire Descriptif des Monument du Cambodge*, Tome I, EFEO, Paris.

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ១៖ ប្រាង្គទាំង៣របស់ប្រាសាទព្រះរកាជន្ទឹង (មើលពីពាយ័ព្យ)



រូបលេខ២៖ ប្រាង្គត្បូង និងកណ្តាលរបស់ប្រាសាទព្រះរកាជន្ទឹង (មើលពីឥសាន្ត)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៣៖ ប្រាង្គត្បូងរបស់ប្រាសាទព្រះរកាជន្ទឹង (មើលពីលិច)



រូបលេខ៤៖ ផ្តែររបស់ទ្វារបញ្ឆោតខាងលិច នៃប្រាង្គខាងត្បូង

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៥៖ ផ្តែរខាងជើងរបស់ប្រាង្គខាងត្បូង



រូបលេខ២៦៖ ប្រាង្គកណ្ដាល (មើលពីខាងលិច)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៧៖ ផ្តែរបស់ទ្វារខាងកើត នៃប្រាង្គកណ្តាល



រូបលេខ៨៖ គ្រឹះឥដ្ឋ និងស៊ុំទ្វារថ្មភក់របស់ប្រាង្គខាងជើង

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា